ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមជ្រូកបាពូជ (ឌុយរ៉ក)



រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)**

ខែមីនា ឆ្នាំ២០២៥

023 220 811
023 220 810
095 416 878
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

# មាតិកា


**១-សេចក្តីផ្តើម** ..... ១

**២-លក្ខណៈទូទៅនៃជ្រូកបាពូង(ខុយរ៉ែក)** ..... ១

**៣-បច្ចេកទេសចិញ្ចឹម** ..... ២

៣-១- ការជ្រើសរើសជ្រើសជ្រូកបា ..... ២

៣-២- ទ្រុងជ្រូកបា ..... ២

៣-៣- សារធាតុចិញ្ចឹមសម្រាប់ជ្រូកបា ..... ៣

៣-៤-វិធានការអនាម័យ និងការថែទាំ ..... ៣

៣-៥- កម្មវិធីវ៉ាក់សាំង ..... ៤

៣-៦- ការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត ..... ៤

៣-៦-១- ការប្រមូលទឹកស្លែមជ្រូក ..... ៥

៣-៦-២- ដំណាក់កាលចេញទឹកស្លែម ..... ៥

៣-៦-៣- ការពិនិត្យមើលទឹកស្លែមដោយម៉ាស៊ីនមីក្រូទស្សន៍ ..... ៦

**៤-ការរៀបចំបណ្តាញផ្សព្វផ្សាយទីផ្សារ តម្លៃ និងសេវាកម្ម** ..... ៧

៤-១- ការរៀបចំបណ្តាញផ្សព្វផ្សាយទីផ្សារ ..... ៧

៤-២- តម្លៃ និងសេវាកម្ម ..... ៧

**៥-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកបាពូង (ខុយរ៉ែក)** ..... ៧

៥-១- ការចំណាយលើការចាប់ផ្តើមអាជីវកម្មដំបូង ..... ៧

៥-២- គម្រោងចំណាយ- ចំណូលលម្អិត និងលទ្ធផល ..... ៨

៥-៣- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ ..... ៩

**៦-ហានិភ័យ វិធានការ និងអនុសាសន៍** ..... ១០

**៧-សេចក្តីសន្និដ្ឋាន** ..... ១១

## ១-សេចក្តីផ្តើម

បច្ចុប្បន្នដោយសារការប្រែប្រួលនៃអាកាសធាតុ ការលេចឡើងនូវជំងឺកាចសាហាវជាបន្តបន្ទាប់ និងស្របពេលដែលបច្ចេកវិទ្យាមានការរីកចម្រើន កសិករចិញ្ចឹមជ្រូកបានអភិវឌ្ឍន៍បច្ចេកទេសតាមបែបបុរាណដែលបង្កាត់រវាងជ្រូកបានិងមេជ្រូកផ្ទាល់ ប្តូរមកអនុវត្តការបង្កាត់ជ្រូកដោយប្រើបច្ចេកទេសថ្មីតាមបែបសិប្បនិម្មិតវិញ ដែលផ្តល់ផលខ្ពស់ជាងមុន កាត់បន្ថយថ្លៃដើមផលិត ងាយស្រួលក្នុងការដឹកជញ្ជូនទៅទីឆ្ងាយ កាត់បន្ថយនូវហានីភ័យនៃការឆ្លងជំងឺ និងអភិវឌ្ឍន៍ពូជជ្រូកល្អៗបានយ៉ាងឆាប់រហ័ស។ ការចិញ្ចឹមជ្រូកបា ទទួលបានប្រាក់ចំណូលច្រើនសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ប្រភេទជ្រូកបាពូជ**ឌុយរ៉ុក** មានការពេញនិយមក្នុងការចិញ្ចឹមនាពេលបច្ចុប្បន្ន ដោយសារជ្រូកពូជនេះធន់នឹងមជ្ឈដ្ឋានដែលស្ថិតនៅជុំវិញបានល្អ ពូកែស៊ីចំណីធំលឿន។ ជ្រូកកូនកាត់រវាងពូជឌុយរ៉ុកជាមួយពូជជ្រូកដទៃទៀត គឺជាជ្រូកដែលចិញ្ចឹមឆាប់ធំ ហើយឱ្យសាច់ក្រហមច្រើន។ កសិករដែលមានបំណងចង់ចិញ្ចឹមជ្រូកបា ត្រូវដឹងពីបច្ចេកទេសចិញ្ចឹម ការជ្រើសរើសជ្រូកបា ការថែទាំ ការផ្តល់ចំណី ការតាមដានការលូតលាស់ល្អ និងការគ្រប់គ្រងការផលិតទឹកកាមរបស់ជ្រូកបា ដើម្បីធានាការបង្កាត់ពូជទទួលបានជោគជ័យ។

## ២-លក្ខណៈទូទៅនៃជ្រូកបាពូជ(ឌុយរ៉ុក)

ពូជជ្រូកឌុយរ៉ុកមានប្រភពមកពីសហរដ្ឋអាមេរិក ត្រូវបានបង្កើតនៅឆ្នាំ ១៨៦០ ហើយបានចែកចាយពាសពេញផ្ទៃប្រទេសអាមេរិកនៅឆ្នាំ១៩៤៧ ដោយការបង្កាត់រវាងពូជជ្រូកនាំចូលពណ៌លឿង Guinea អាហ្វ្រិច និងពូជជ្រូកលឿងអេស្ប៉ាញ ។

**ពូជជ្រូកឌុយរ៉ុកនេះមាន÷**



- មាឌមាំ រហ័សរហួន ពណ៌ត្នោតចាស់ ឬខ្ចី
- ជើងធំវែង ធន់នឹងជំងឺ អត្រាសាច់ក្រហមច្រើន
- ត្រចៀកធ្លាក់បន្តិចទៅមុខ សាយកូនមានពី៨ ទៅ១០ក្បាល ក្នុងមួយសំបុក/សារ
- មានក្រចក និងច្រមុះ ភ្នាសភ្នែកពណ៌ខ្មៅ
- ពូជជ្រូកនេះកសិករចិញ្ចឹមច្រើនយកទៅបង្កាត់ជាមួយពូជជ្រូកដទៃទៀត ដើម្បីទទួលបានសាច់ក្រហមច្រើន ហើយកូនជ្រូកចិញ្ចឹមឆាប់ធំ។

## ៣-បច្ចេកទេសចិញ្ចឹម

### ៣-១-ការជ្រើសរើសជ្រូកបា

ការជ្រើសរើសជ្រូកបាមានសារៈសំខាន់ណាស់ដើម្បីបំពេញតម្រូវការទាំងបរិមាណនិងគុណភាពនៃផលិតកម្ម។ ជ្រូកបាដែលល្អ ត្រូវមានលក្ខណៈដូចខាងក្រោម÷

- មានសុខភាពល្អ ស្រែកឮ មានភាពរហ័សរហួន
- រូបរាងល្អ មានមាឌមាំ ដងខ្លួនវែង ជើងទាំងបួនធំហើយមាំ ត្រគាកសាយ
- ពងស្វាសទាំង២ធំ ហើយមានទំហំប៉ុនគ្នា
- មានរោមក្រាស់ និងរលោងភ្លឺ
- ពុំមានប្រវត្តិឆ្លងជំងឺពីមុនមក
- មានប្រភពច្បាស់លាស់ កសិករអ្នកចិញ្ចឹមត្រូវជ្រើសរើសយកកូនជ្រូកសារទី២
- បានចាក់ថ្នាំបង្ការ (វ៉ាក់សាំង) ឱ្យបានត្រឹមត្រូវតាមកាលកំណត់
- ធន់នឹងបរិស្ថានអាកាសធាតុក្នុងស្រុក
- ដែលអាចរកទិញបានក្នុងស្រុក និងជាពូជពេញនិយម
- ប្រភេទជ្រូកបាដែលចាត់ទុកថាល្អ គឺមានអាយុចាប់ពី ៧ទៅ៨ខែឡើងទៅ

### ៣-២-ទ្រុងជ្រូកបា

ការសាងសង់ទ្រុងជ្រូកបា ត្រូវតែមានលក្ខណៈរឹងមាំ ដែលទប់ទល់នឹងកម្លាំងខ្លាំងក្លារបស់ជ្រូក គួរប្រើដែកទីបស្វិតមាំ ដូចទ្រុងមេជ្រូកផងដែរ÷

- ជ្រូកបាអាចនៅក្នុងទ្រុងលាត ដែលមានទំហំ ២ម៉ែត្រ គុណ៣ម៉ែត្រ កម្ពស់ ១,៤០ម៉ែត្រ និងមានចន្លោះរបារដែកទីបពីមួយ ទៅមួយ ០,១ម៉ែត្រ។
- ទ្រុងសម្រាប់ប្រមូលទឹកស្លែមមានទំហំ ១,៥ម៉ែត្រ គុណ៣ម៉ែត្រ
- ត្រូវមានទីធ្លាដែលអាចឱ្យជ្រូកអាចដើរបានដើម្បីជៀសវាងភាពស្ពឹកស្រពន់ និងលាមកក្តៀន
- ការការពារកម្តៅ ត្រូវមានខ្យល់ចេញចូល ពន្លឺគ្រប់គ្រាន់ និងមានសីតុណ្ហភាពទាប

## ៣-៣- សារធាតុចិញ្ចឹមសម្រាប់ជ្រូកបា

គឺជាជីវជាតិមាននៅក្នុងចំណីដែលជ្រូកត្រូវការ÷ ទឹក ថាមពល ប្រូតេអ៊ីត (ជាតិសាច់) រ៉ែ និងវិតាមីន។ កសិករអាចប្រើប្រាស់ចំណីសម្រេចសម្រាប់មេជ្រូកក្រមុំ ដែលត្រៀមបង្កាត់ក៏បានជាមធ្យមចំនួន ៣គីឡូក្រាម/ថ្ងៃ សម្រាប់ជ្រូកបា១ក្បាល ។




**តារាងផ្តល់ចំណី**

| ទម្ងន់ជ្រូកបា (គីឡូក្រាម) | តូចជាង ១៥៩ | ១៥៩ | ២០៥ | ២៥០ | ២៩៥ | ៣៤១ |
|---|---|---|---|---|---|---|
| ទម្ងន់ចំណី (គីឡូក្រាម/១ថ្ងៃ) | ២ | ២,៥ | ២,៧ | ៣,០ | ៣,៣ | ៣,៥ |

## ៣-៤-វិធានការអនាម័យ និងការថែទាំ

ជ្រូកបាត្រូវចំណាយកម្លាំងច្រើនក្នុងការបង្កាត់ពូជដូច្នេះជ្រូកបាត្រូវមានសុខភាពល្អជាចាំបាច់។ កសិករចិញ្ចឹមត្រូវថែទាំជ្រូកបាដូចខាងក្រោម÷

- ត្រួតពិនិត្យសុខភាពជ្រូក ២ដង/ថ្ងៃ ដោយប្រើទែរម៉ូម៉ែត្រស្ទង់កម្តៅខ្លួនជ្រូក
- ក្រោយពីដាក់ចំណីត្រូវលាងសម្អាតទ្រុង ២ទៅ៣ដង/ថ្ងៃ និងទឹកផឹកដោយសេរី
- ទឹកស្លែមជ្រូកបា ត្រូវបានបង្កាត់ជាមួយមេជ្រូកជាច្រើន ដូច្នេះជ្រូកបាត្រូវមានសុខភាពល្អ
- ពិនិត្យការស៊ីចំណីរបស់ជ្រូក និងអាកប្បកិរិយានៃការបញ្ចេញទឹកស្លែម
- កម្មវិធីវ៉ាក់សាំងការពារឱ្យបានទៀងទាត់
- ត្រួតពិនិត្យសុខភាពជ្រូកជាប្រចាំ មិនត្រូវបង្ខំបង្កាត់ពូជនៅពេលជ្រូកមានសុខភាពមិនល្អ
- សម្ភារៈសម្រាប់បង្កាត់ពូជ ត្រូវសម្លាប់មេរោគជាមុន
- ក្នុងទ្រុងត្រូវស្អាត ស្ងួត និងមានអនាម័យជាប្រចាំ
- ត្រូវធ្វើរបង មិនត្រូវអនុញ្ញាតឱ្យអ្នកក្រៅចេញចូលប៉ះពាល់ជ្រូកឡើយ
- ចំពោះបុគ្គលិកដែលដើរបង្កាត់ជ្រូកច្រើនកន្លែងត្រូវមុជទឹកសម្អាតខ្លួន ស្លៀកសំលៀកបំពាក់របស់កសិដ្ឋាន និងត្រូវជ្រលក់ជើងក្នុងទឹកសម្លាប់មេរោគ
- វិធានការជីវៈសុវត្ថិភាព

## ៣-៥- កម្មវិធីវ៉ាក់សាំង

ការចាក់វ៉ាក់សាំងឱ្យជ្រូកបាគឺសំខាន់បំផុត ដើម្បីធានាឱ្យបាននូវសុខភាព និងទឹកស្លែម។ កម្មវិធីវ៉ាក់សាំងសម្រាប់ជ្រូកបាត្រូវធ្វើឡើងឱ្យបាន២ដង/ឆ្នាំ ។ វ៉ាក់សាំងដែលត្រូវធ្វើ មាន៖ ប៉េស្ត កញ្ជ្រិល អុតក្តាម អូហ្សេស្គី និងសារទឹក ដោយកម្មវិធីទាំងនេះអនុវត្តនៅពេលជ្រូកមានអាយុចាប់ពី៦ខែឡើង កសិករត្រូវតាមដានឱ្យបានត្រឹមត្រូវ ច្បាស់លាស់ ក្រៅពីនេះមានកម្មវិធីទម្លាក់បរាសិត រៀងរាល់ ៦ខែម្តងថែមទៀត។

## ៣-៦- ការបង្កាត់ពូជជ្រូកដោយសិប្បនិម្មិត

គឺជាការបន្តពូជដោយប្រយោល ដោយគ្រាន់តែយកទឹកស្លែមពីបាជ្រូកមកត្រួតពិនិត្យ លាយចំណីចិញ្ចឹមថែទាំ និងត្រូវរក្សាទុកក្នុងកម្រិតដែលធានាឱ្យមានសុវត្ថិភាព កំហាប់ និងគុណភាពរបស់ស្ពែម៉ាតូស្ហ៊ីត (មេជីវិតឈ្មោល) ហើយយកទៅដាក់បញ្ចូលក្នុងប្រព័ន្ធបន្តពូជជ្រូកញីដែលកំពុងរកឈ្មោលស៊ប់។

### ក- អត្ថប្រយោជន៍នៃការបង្កាត់ពូជសិប្បនិម្មិត

- មិនប្រើបាជ្រូកពាក់លើមេជ្រូកដោយផ្ទាល់
- ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺដល់មេជ្រូក និងបាជ្រូក ពិសេសជំងឺ ដែលបង្កលើប្រដាប់បន្តពូជ និងប្រដាប់ដកដង្ហើម
- មិនបង្កឱ្យមានគ្រោះថ្នាក់ដល់មេជ្រូកដូចជា៖ គ្រិចជើង ថ្លោះ ឬបាក់ចង្កេះនៅពេលដែលបាជ្រូកមានទម្ងន់ធ្ងន់ ឡើងពាក់ពីលើ
- មិនចាំបាច់ដឹកបាជ្រូកទៅដល់កន្លែងមេជ្រូក (ទប់ស្កាត់ការឆ្លងជំងឺឆ្លង ពីកន្លែងមួយទៅមួយ)
- ទឹកស្លែមត្រូវបានពិនិត្យគុណភាពត្រឹមត្រូវ (ដោយប្រើមីក្រូទស្សន៍) មុនពេលដាក់បង្កាត់
- កែច្នៃពូជជ្រូកប្រកបដោយភាពជឿនលឿន
- ការបង្កាត់សិប្បនិម្មិតនាំយកពូជជ្រូកល្អៗទៅផ្តល់ដល់កសិករចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ
- ប្រើប្រាស់បាជ្រូកតិច គឺកាត់បន្ថយការចំណាយ

### ខ- គុណវិបត្តិនៃការបង្កាត់ពូជសិប្បនិម្មិត

- អាចជាន់ឈាម ប្រសិនបើកសិករកត់ត្រាប្រវត្តិសត្វជ្រូកមិនច្បាស់លាស់
- ងាយនឹងចម្លងជំងឺផ្សេងៗប្រសិនបើការត្រួតពិនិត្យជំងឺមិនបានត្រឹមត្រូវ
- ទាមទារបច្ចេកទេស សម្ភារៈច្រើន និងបទពិសោធន៍ខ្ពស់ក្នុងការបង្កាត់ពូជ

## ៣-៦-១-ការប្រមូលទឹកស្លេមជ្រូក





**របៀបយកទឹកស្លេមដោយប្រើដៃ** **យកទឹកស្លេមដោយប្រើឧបករណ៍ផ្ទាក់ស្វ័យប្រវត្តិ**

បាជ្រូកដែលយកមកឡើងផ្ទាក់ផលិតស្លេមត្រូវមានអាយុយ៉ាងហោចណាស់ចាប់ពី ៧ខែឡើងទៅ អាចរហូតដល់អាយុ៤ឆ្នាំ។ មុនពេលយកទឹកស្លេម កសិករចិញ្ចឹមត្រូវធ្វើអនាម័យលាងសម្អាតដងខ្លួន និងផ្នែកក្រោមលិង្គរបស់បាជ្រូក ដោយត្រូវធ្វើនៅទីតាំងក្នុងទ្រុងដែលស្ងួត និងមិនរអិល។ កន្លែងយកទឹកស្លេមត្រូវតែស្ងាត់ស្ងៀមជៀសវាងអ្នកចូលមើលច្រើន។

## ៣-៦-២-ដំណាក់កាលបញ្ចេញទឹកស្លេម

ជ្រូកបាបញ្ចេញទឹកស្លេមជា៣ដំណាក់កាលបន្តបន្ទាប់គ្នា÷

- ដំណាក់កាលទី១÷ ទឹកស្លេម (ពណ៌សខាប់ និងមានក្លិន) ហើយមានចំនួន ២៥សេសេ
- ដំណាក់កាលទី២÷ ស្លេមច្រើន ចំនួនពី៤០ ទៅ១០០សេសេ ហើយមានមេជីវិតពី៨០ទៅ៩០%
- ដំណាក់កាលទី៣÷ ស្លេមច្រើនលើសលុប ពី៧០ ទៅ៤០០ សេសេ គុណភាពស្លេមមិនសូវល្អ

<u>***កំណត់សំគាល់***</u> ÷

- ➢ កន្លែងយកទឹកស្លេម ត្រូវតែស្ងាត់ស្ងៀមជៀសវាងអ្នកចូលមើលច្រើន
- ➢ អ្នកប្រមូលយកស្លេមត្រូវមានបច្ចេកទេសអនុវត្តឱ្យបានត្រឹមត្រូវ
- ➢ ត្រូវប្រាកដថាទឹកស្លេមមានគុណភាពល្អ
- ➢ ត្រូវចាប់លិង្គជ្រូកដោយប្រុងប្រយ័ត្ន និងលាងសម្អាតសម្លាប់មេរោគនៅលិង្គ
- ➢ ការយកស្លេមដោយប្រើដៃ ឬឧបករណ៍ មិនត្រូវយកដៃប៉ះពាល់ទឹកស្លេមឡើយ
- ➢ ករណីទឹកស្លេមបាញ់ចេញខាប់ដូចម្សៅ (ដូចគ្រាប់សាគូ) ត្រូវយកចោល






កម្រិតកំណត់ក្នុង១ដូស មាន៣កោដិមេជីវិត ចំណុះ១ដូស ពី៨០ ទៅ១០០សេសេ ដោយលាយស្ពែម ជាមួយល្បាយលុយស្យុងនៅសីតុណ្ហភាព ៣៧អង្សាសេ សមាមាត្រនៃការលាយពី ១/៥ ទៅ ១/២០។

**ចំណាំ**÷

- បើជ្រូកបាមានបញ្ហាគ្រុនក្តៅខ្លាំងដោយសារជំងឺឆ្លង ៣សប្តាហ៍ក្រោយមកជ្រូកបានឹងមានសុខភាពល្អឡើងវិញ តែទឹកស្ពែមរបស់វាមិនមានគុណភាពមេជីវិតទេ
- ជ្រូកបាបង្កាត់មេរាល់ថ្ងៃនោះដង់ស៊ីតេ និងសកម្មភាពរបស់មេជីវិតឈ្មោលមានកម្រិតទាប ហើយជានិច្ចកាលមិនសមស្របសម្រាប់ការផលិតកូនជ្រូកឱ្យបានច្រើននោះទេ
- ទឹកស្ពែមចាំបាច់ត្រូវពិនិត្យតាមមីក្រូទស្សន៍គ្រប់ពេលទាំងអស់ ដើម្បីធានាគុណភាព
- ត្រូវធានាថាសម្ភារៈទាំងអស់ត្រូវបានសម្លាប់មេរោគ ជាពិសេស ដប និងកែវដាក់ទឹកស្ពែម

### ៣-៦-៣-ការពិនិត្យមើលទឹកស្ពែមដោយម៉ាស៊ីនមីក្រូទស្សន៍

ចំនួនស្ពែមដែលយកបានពី ១៥០ ទៅ៤០០សេសេ អាស្រ័យទៅតាម ÷ អាយុរបស់ជ្រូកបា មានឧបច្ចេកទេសប្រមូលស្ពែម ពូជ និងចំណីអាហារ។



**ចំណាំ**÷

ទឹកស្ពែម មានគុណភាពអន់ដោយសារ÷

-ប្រើប្រាស់ជ្រូកបាមានអាយុក្មេងពេក ហើពងស្វាសរបស់ជ្រូកលូតលាស់មិនទាន់ពេញលេញ

-ប្រើបាជ្រូកឱ្យពាក់មេច្រើនដងពេក

-ដោយសារអាកាសធាតុក្តៅពេក

ត្រូវរៀបចំដូសទឹកស្ពែមចំណុះពី ៨០ ទៅ១០០សេសេ ទុកក្នុងទូទឹកកក ក្នុងសីតុណ្ហភាពពី ១៦ ទៅ១៨ អង្សារសេ ដោយរក្សាទុកមិនឱ្យលើសពី ៥ថ្ងៃឡើយ។

## ៤-ការរៀបចំបណ្ដាញផ្សព្វផ្សាយទីផ្សារ តម្លៃ និងសេវាកម្ម

### ៤-១-ការរៀបចំបណ្ដាញផ្សព្វផ្សាយទីផ្សារ

ដើម្បីស្វែងរកអតិថិជនឱ្យបានច្រើនកសិករដែលបង្កាត់ជ្រូកតាមបែបសិប្បនិម្មិតគួររៀបចំបណ្ដាញផ្សព្វផ្សាយ និងលក់ផលិតផលទឹកស្ពែម ដោយត្រូវមានទំនាក់ទំនងល្អជាមួយមន្ត្រីបសុព្យាបាលថ្នាក់ស្រុក ថ្នាក់ឃុំ ជាពិសេសភ្នាក់ងារសុខភាពសត្វភូមិ និងអ្នកប្រកបរបរចិញ្ចឹមជ្រូក។

### ៤-២-តម្លៃ និងសេវាកម្ម

សេវាកម្មល្អគឺជាមធ្យោបាយទាញយកអតិថិជនឱ្យបានច្រើន អ្នកបង្កាត់សិប្បនិម្មិតជ្រូកគួរពិចារណាលើតម្លៃឱ្យបានសមរម្យ ដោយរាប់បញ្ចូលទាំងការដឹកជញ្ជូន គុណភាពផលិតផល និងសេវាគាំទ្រ។ តម្លៃបង្កាត់សិប្បនិម្មិតអាចចាប់ពី ៤៣,០០០រៀល ទៅ ៥០,០០០រៀលសម្រាប់មេជ្រូក១ក្បាល។ ឯតម្លៃដែលកសិករទិញទឹកស្ពែមទៅបង្កាត់ដោយខ្លួនឯងពី ២២,០០០រៀល ទៅ២៦,០០០រៀលសម្រាប់មេជ្រូក១ក្បាល។

## ៥-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកបាពូជ (ឌុយរ៉ុក)

**កសិករ** ៖ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប

**ទំហំផ្ទៃដីចិញ្ចឹម** ៖ ៥០ អា ( ៥,០០០ ម៉ែត្រការ៉េ )

**ចំនួនជ្រូកបា** ៖ ជ្រូកបាចំនួន២ក្បាល អាយុ១០ខែ សម្រាប់ផ្គត់ផ្គង់ទឹកស្ពែម (ពូជឌុយរ៉ុក)

**របៀបចិញ្ចឹម** ៖ ចិញ្ចឹមក្នុងរោង និងផ្ដល់ចំណីផ្សំស្រេច

**ទិន្នផលទឹកស្ពែម** ៖

-ជ្រូកបាមានអាយុចាប់ពី១០ខែ ទៅ២២ខែអាចផ្ដល់ទឹកស្ពែម១ដងក្នុងរយៈពេល៣ថ្ងៃ

-ចាប់ពីអាយុ ២២ខែ ទៅ៣៦ខែ ជ្រូកអាចផ្ដល់ទឹកស្ពែមបាន ៣ដង/សប្ដាហ៍/ក្បាល (ទឹកស្ពែមយកពីជ្រូកបាម្ដងដោយលាយបន្ថែមសូលុយស្យុងអាចបង្កាត់មេជ្រូកបានចន្លោះពី៤ ទៅ៥ក្បាល)

**រយៈពេលផ្ដល់ទឹកស្ពែម**៖ ជ្រូកបា១ក្បាលអាចផ្ដល់ទឹកស្ពែមមានគុណភាពល្អរយៈពេល ៣ឆ្នាំ

### ៥-១-ចំណាយលើការចាប់ផ្ដើមអាជីវកម្មដំបូង៖

| ទុនវិនិយោគសាងសង់រោង ជ្រូកបាពូជ មីក្រូទស្សន៍ និងសម្ភារៈផ្សេងៗ | ទុនសម្រាប់ចិញ្ចឹម ថែទាំក្នុងរយៈពេល៣ឆ្នាំ (រៀល) | ទឹកប្រាក់សរុប(រៀល) |
|---|---|---|
| 16,635,000 | 74,626,800 | **91,261,800** |

## ៥-២-គម្រោងចំណាយ-ចំណូលលម្អិត និងលទ្ធផល÷

ការចិញ្ចឹមជ្រូកបា២ក្បាលសម្រាប់ផលិតទឹកស្ពែមដើម្បីបង្កាត់សិប្បនិម្មិតរយៈពេល៣ឆ្នាំ

*-ចំណូលពីការបង្កាត់សិប្បនិម្មិត÷សំដៅលើការផ្តល់សេវាបង្កាត់ដល់អតិថិជន ដោយម្ចាស់ជ្រូកបាយកទឹកស្ពែមទៅដាក់បង្កាត់មេជ្រូកតាមបែបសិប្បនិម្មិត (ពុំមានការបង្កាត់ផ្ទាល់រវាងជ្រូកបា និងមេជ្រូកឡើយ) ។*

*-ចំណូលពីការលក់ទឹកស្ពែម÷សំដៅលើម្ចាស់ជ្រូកបា លក់ទឹកស្ពែមដែលផលិតបានទៅអតិថិជនចិញ្ចឹមជ្រូកមេ ដោយម្ចាស់ជ្រូកមេបង្កាត់យកខ្លួនឯង។*

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ១ឯកត្តា | ទឹកប្រាក់សរុប ( ៛ ) | ចំនួនសារវ៉លស់ | ទឹកប្រាក់សរុប ( ៛ ) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីបាជ្រូក** | | | | | | **146,002,500** |
| ចំណូលពីការបង្កាត់សិប្បនិម្មិត | ក្បាល | 2,457 | 46,500 | 114,250,500 | | **114,250,500** |
| ចំណូលពីការលក់ទឹកស្ពែមជ្រូក | ក្បាល | 1,323 | 24,000 | 31,752,000 | | **31,752,000** |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **85,213,694** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **74,626,800** |
| ចំណីសម្រេចជ្រូកបា (ឬប្រើចំណីមេក្រុម៉ុ) | គ.ក | 6,570 | 2,330 | 15,308,100 | | 15,308,100 |
| ប្រេងសាំងសម្រាប់ផ្តល់សេវាកម្មបង្កាត់តាមផ្ទះ | លីត្រ | 1,095 | 4,500 | 4,927,500 | | 4,927,500 |
| ចំណីស្ពែមលាយសូលុយស្យុង | កញ្ចប់ | 840 | 10,000 | 8,400,000 | | 8,400,000 |
| ទឹកសម្រាប់លាយស្ពែម | ដប | 560 | 2,300 | 1,288,000 | | 1,288,000 |
| លិង្គសិប្បនិម្មិត និងដបដាក់ទឹកស្ពែម | ចំនួន | 3,780 | 3,800 | 14,364,000 | | 14,364,000 |
| ថ្លៃអគ្គិសនី | គី/វ៉ាត | 360 | 720 | 259,200 | | 259,200 |
| វ៉ាក់សាំងជ្រូកបា | ក្បាល | 2 | 100,000 | 200,000 | | 200,000 |
| កំលាំងពលកម្ម | នាក់ខែ | 36 | 800,000 | 28,800,000 | | 28,800,000 |
| ថ្នាំសំលាប់មេរោគ | ខែ | 36 | 30,000 | 1,080,000 | | 1,080,000 |

| | | | | | | |
|---|---|---|---|---|---|---|
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង៣ឆ្នាំ)** | | | | **16,635,000** | | **10,586,894** |
| រោងជ្រូក ស្តុកចំណី ក្បាលបឺតទឹក ទុយោរទឹក ។ល។ | រោង | 1 | 6,000,000 | 6,000,000 | 3.3 | 1,818,182 |
| ម៉ូទ័របូមទឹក ប្រើបាន៥ឆ្នាំ | គ្រឿង | 1 | 400,000 | 400,000 | 2 | 250,000 |
| ផ្ទាក់សិប្បនិម្មិត | គ្រឿង | 1 | 100,000 | 100,000 | 10 | 10,000 |
| ស្រះទឹកសម្រាប់បង្ហូរលាមក | ចំនួន | 1 | 200,000 | 200,000 | 5 | 40,000 |
| ទូទឹកកក | គ្រឿង | 1 | 400,000 | 400,000 | 3.3 | 121,212 |
| មីក្រូទស្សន៍ និងសម្ភារៈពិនិត្យចលនាស្ពែម | គ្រឿង | 1 | 1,400,000 | 1,400,000 | 5 | 280,000 |
| ធុងបាញ់ថ្នាំសំលាប់មេរោគ | ធុង | 1 | 100,000 | 100,000 | 2 | 50,000 |
| បាជ្រូក | ក្បាល | 2 | 4,000,000 | 8,000,000 | 1 | 8,000,000 |
| ទុយោទឹក | ដុំ | 1 | 35,000 | 35,000 | 2 | 17,500 |
| **៣-ចំណេញសរុបរយៈពេល៣ឆ្នាំ** | | | | | | **60,788,806** |
| **ថ្លៃដើមផលិតទឹកស្ពែមបង្កាត់មេជ្រូក/ក្បាល** | | | | | | **22,543** |
| **ប្រាក់ចំណេញក្នុង១ខែ** | | | | | | **1,688,578** |

### ៥-៣- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់:

កសិករចិញ្ចឹមជ្រូកបានៅឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទទួលបានតម្លៃសេវាបង្កាត់សិប្បនិម្មិតជាមធ្យមគឺ ៤៦,៥០០៛/ក្បាល និងតម្លៃលក់ទឹកស្ពែមជូនម្ចាស់ជ្រូកមេទៅបង្កាត់ដោយខ្លួនឯងជាមធ្យមគឺ ២៤,០០០៛/ក្បាល តម្លៃទាំងនេះអាចនឹងប្រែប្រួលឡើងចុះទៅតាមតំបន់ផ្សេងៗអាស្រ័យនិន្នាការតម្រូវការទីផ្សារ ដូចជា÷តម្លៃជ្រូកសាច់លក់នៅទីផ្សារ និងបរិមាណនៃការចិញ្ចឹមមេជ្រូកក្នុងតំបន់។

| ចំណូលពីសេវាបង្កាត់ និងលក់ទឹកស្ពែមឱ្យម្ចាស់បង្កាត់ខ្លួនឯង | | | | | ចំណាយ | ចំណេញ-ខាត | |
|---|---|---|---|---|---|---|---|
| សេវាបង្កាត់ | | លក់ទឹកស្ពែម | | សរុប (៛) | សរុប (៛) | (៛) | % |
| តម្លៃ (៛) | មេជ្រូក | តម្លៃ (៛) | មេជ្រូក | | | | |
| 22,543 | 2,457 | 22,543 | 1323 | 85,213,694 | 85,213,694 | 0 | 0% |
| 30,000 | 2,457 | 24,000 | 1323 | 105,462,000 | 85,213,694 | 20,248,306 | 24% |
| 35,000 | 2,457 | 24,000 | 1323 | 117,747,000 | 85,213,694 | 32,533,306 | 38% |
| 40,000 | 2,457 | 24,000 | 1323 | 130,032,000 | 85,213,694 | 44,818,306 | 53% |
| 46,500 | 2,457 | 24,000 | 1323 | 146,002,500 | 85,213,694 | 60,788,806 | 71% |
| 48,000 | 2,457 | 26,000 | 1323 | 152,334,000 | 85,213,694 | 67,120,306 | 79% |
| 50,000 | 2,457 | 28,000 | 1323 | 159,894,000 | 85,213,694 | 74,680,306 | 88% |

## ៦-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះសិក្សានៅកសិដ្ឋានចិញ្ចឹមជ្រូកបា ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឃើញថាដំណើរការអាជីវកម្មរបស់កសិករ អាចជួបនូវហានីភ័យមួយចំនួនជាយថាហេតុលើដំណើរការចិញ្ចឹមជ្រូកបាដែលនាំឱ្យបង្កផលវិបាក និងប៉ះពាល់ដល់ផលិតកម្ម ដូចនេះកសិករគួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងលើហានីភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់ ÷

| ល.រ | ប្រភេទ ហានិភ័យ | ការពិពណ៌នា ពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យ ផលិតកម្ម | ជ្រូកធ្លាប់មានជំងឺពីតូច<br>ជាន់ឈាមពីម្ចាស់មុន<br>ទឹកស្ពែមមានកំហាប់<br>ស្ពែមម៉ាតូសូអ៊ីតទាប<br>ចលនាមិនសូវល្អ<br>បរិមាណទឹកស្ពែមតិច | -ត្រូវជ្រើសរើសជ្រូកបាចេញពីកសិដ្ឋានដែលមានបង្កាត់ពូជច្បាស់លាស់ មានធានាលើពូជ<br>-មានការធានាលើគុណភាពទឹកស្ពែម<br>-មានពងស្វាសធំៗប៉ុនគ្នា<br>-ផ្តល់ចំណីមានគុណភាពដើម្បីផលិតទឹកស្ពែមបានល្អ<br>- ត្រូវរៀបចំទ្រុងឱ្យបានសមស្របតាមបច្ចេកទេស |
| | | តម្លៃចំណីមានការកើនឡើង | -ត្រូវស្វែងរកប្រភពចំណីមានតម្លៃទាប<br>-ត្រូវមានជម្រើសចំណី ២ទៅ៣ក្រុមហ៊ុនលក់ចំណីសត្វ<br>-ធ្វើការពិសោធន៍លើការផ្តល់ចំណីផ្សំដោយខ្លួនឯង |
| ២ | ហានិភ័យ ទីផ្សារ | -តម្រូវការទីផ្សារប្រែប្រួលទៅតាមបរិមាណ | -ស្វែងរកដៃគូសហការក្នុងដំណើរការអាជីវកម្ម<br>-ស្វែងរកកសិដ្ឋានដែលមានមេជ្រូកច្រើនៗបន្ថែមទៀត |

| | | | |
|---|---|---|---|
| | | ចិញ្ចឹមដោយផ្អែកលើតម្លៃជ្រូកសាច់នៅទីផ្សារ | -ផ្តល់ការផ្គត់ផ្គង់សេវាកម្មល្អ និងច្បាស់លាស់<br>-នាំចូលជ្រូកបាពូជថ្មីៗ ដែលជាតម្រូវការរបស់អតិថិជន<br>-មានការផ្សព្វផ្សាយឱ្យទូលំទូលាយ<br>-មានភាពស្មោះត្រង់ និងទំនុកចិត្តដល់អតិថិជន |
| ៣ | **ហានិភ័យហិរញ្ញវត្ថុ** | មិនមានប្រាក់បម្រុងសម្រាប់ទប់ទល់ហេតុការណ៍កើតឡើងដោយចៃដន្យ | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-កំណត់បរិមាណចិញ្ចឹមទៅតាមទំហំទុន<br>-មានផែនការលក់វិលជុំ ដើម្បីទទួលបានប្រាក់ចំណូលទៀងទាត់ |
| ៤ | **ហានិភ័យបរិស្ថាន** | មានក្លិនស្អុយ និងសម្លេងរំខានប៉ះពាល់ដល់អ្នកជិតខាង | -ជ្រើសរើសទីតាំងដែលឆ្ងាយពីផ្ទះអ្នកជិតខាត<br>-ត្រូវធ្វើអនាម័យសម្អាតទ្រុងជាប្រចាំ និងមានទីស្តុកលាមកជ្រូកឱ្យបានត្រឹមត្រូវ<br>-អាចសង់ជាឡជីវឧស្ម័នសម្រាប់ប្រើប្រាស់ទៀតផង |

## ៧-សេចក្តីសន្និដ្ឋាន

ការចិញ្ចឹមជ្រូកបាគឺជារបរសំខាន់ក្នុងវិស័យចិញ្ចឹមជ្រូក និងអភិវឌ្ឍពូជជ្រូក ដែលអាចផ្តល់ប្រាក់ចំណូលសមរម្យសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។ ការចិញ្ចឹមជ្រូកបាមានភាពងាយស្រួលច្រើន ដោយសារជ្រូកបាមានភាពធន់នឹងអាកាសធាតុ ជំងឺ ហើយងាយស្រួលថែទាំ រីឯការផ្តល់ចំណីគឺអាចផ្តល់ជាចំណីសម្រេច ឬចំណីផ្សំដោយខ្លួនឯង។ មុនចាប់ផ្តើមប្រកបរបរនេះ កសិករគួរយល់ដឹងឱ្យបានច្បាស់នូវបច្ចេកទេសចិញ្ចឹម ជាពិសេសបច្ចេកទេសថ្មីៗមួយចំនួនដែលសមស្របទៅនឹងការប្រែប្រួលអាកាសធាតុ ការជ្រើសរើសពូជ របៀបធ្វើទ្រុង របៀបយកទឹកស្លែមដោយប្រើធ្នាក់ ការលាយទឹកស្លែមសម្រាប់បង្កាត់ របៀបពិនិត្យចលនាស្លែមតាមរយៈការប្រើប្រាស់មីក្រូទស្សន៍ របៀបបង្កាត់មេជ្រូកតាមបែបសិប្បនិម្មិត បច្ចេកទេសផ្តល់ចំណី កម្មវិធីវ៉ាក់សាំង ការថែទាំ និងការពារជាដើម ទើបអាចទទួលបានទឹកស្លែមជ្រូកដែលមានគុណភាពខ្ពស់។

**<u>ប្រភពនៃការសិក្សាស្រាវជ្រាវ</u>÷**

១/-ចុះសិក្សាដោយផ្ទាល់ជាមួយកសិករចិញ្ចឹមជ្រូកបា នៅឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប

២/-សៀវភៅណែនាំបច្ចេកទេសស្តីពី ការបង្កាត់សិប្បនិម្មិតជ្រូក (គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប)

៣/-ការបង្កាត់សិប្បនិម្មិតជ្រូក (អ៊ិត ម៉ាណយ ស៊ុន សូត គឹមសាន សុភ័ណ្ឌ)

៤/- <u>Duroc Pig: Origin, Characteristics, Size, Color, Weight</u>